ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៣៩ សសរ

ក្រសួងមុខងារសាធារណៈ
រដ្ឋបាល
ចូល
លេខ: ៤១៥៦
មកដល់ថ្ងៃទី៣ ខែ០៥ ឆ្នាំ១៧
ម៉ោង ៨:០៥

# សេចក្តីសម្រេច

## ស្តីពី

## ការរៀបចំផ្ទេរមុខងារជាក់លាក់នានាទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលសមាសភាពសមាជិករាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- យោងតាមសំណើប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

# សម្រេច

**ប្រការ ១.-**

ត្រូវបានសម្រេចឱ្យមានការរៀបចំផ្ទេរមុខងារចំនួន២៨ពីក្រសួង ស្ថាប័នក្នុងវិស័យអាទិភាពនានាទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ដូចមានកំណត់នៅក្នុងឧបសម្ព័ន្ធនៃសេចក្ដីសម្រេចនេះ។

**ប្រការ ២.-**

ក្រសួង ស្ថាប័នពាក់ព័ន្ធនានាត្រូវទទួលខុសត្រូវក្នុងការរៀបចំលិខិតបទដ្ឋានគតិយុត្តនានា ដើម្បីផ្ទេរមុខងារដែលពាក់ព័ន្ធទៅនឹងក្រសួង ស្ថាប័នរបស់ខ្លួនទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយមានការសម្របសម្រួលពីគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

**ប្រការ ៣.-**

ការផ្ទេរមុខងារទាំងនេះទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិនានាត្រូវអនុវត្តទៅតាមដំណាក់កាល ដូចបានកំណត់នៅក្នុងតារាងឧបសម្ព័ន្ធនៃសេចក្ដីសម្រេចនេះ និងត្រូវចាប់ផ្ដើមអនុវត្តចាប់ពីឆ្នាំ២០១៧នេះតទៅ។

**ប្រការ ៤.-**

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ មានភារកិច្ចដឹកនាំ និងសម្របសម្រួលកិច្ចដំណើរការនេះ និងត្រូវធ្វើសេចក្ដីរាយការណ៍ជាប្រចាំអំពីលទ្ធផលនៃការរៀបចំផ្ទេរមុខងារទាំងនេះជូនរាជរដ្ឋាភិបាល។

**ប្រការ ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី ប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសម្រេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ÷**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធភ្ជាប់ជាមួយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ.៣៦៩..ស.ស.រ..ចុះថ្ងៃទី២២ ខែ ១.៩.៣. ឆ្នាំ២០១៧
ស្តីពីការរៀបចំផ្ទេរមុខងារជាក់លាក់នានាទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ

## I. បញ្ជីមុខងារក្នុងវិស័យសុខាភិបាលដែលត្រូវផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ

| ល.រ | មុខងារ/កិច្ចការ | រដ្ឋបាលថ្នាក់ជាតិ | រដ្ឋបាលថ្នាក់រាជធានី ខេត្ត | រដ្ឋបាលថ្នាក់ក្រុងស្រុក | ដំណាក់កាលផ្ទេរ |
|---|---|---|---|---|---|
| ១ | **ការគ្រប់គ្រង និងការផ្តល់សេវានៃមន្ទីរសុខាភិបាលរាជធានី ខេត្ត** | | | | |
| ១.១. | រៀបចំគោលនយោបាយ និងផែនការ | - រៀបចំគោលនយោបាយជាតិវិស័យសុខាភិបាល<br>- អភិវឌ្ឍផែនការ និងយុទ្ធសាស្ត្រសម្រាប់វិស័យសុខាភិបាល<br>- អភិវឌ្ឍវិធាន និយតកម្ម និងគោលការណ៍ណែនាំ ដើម្បីបង្កើនគុណភាពសេវាសុខភាពជាអតិបរមាទាំងនៅផ្នែកសាធារណៈ និងឯកជន<br>- កំណត់លក្ខណៈវិនិច្ឆ័យសម្រាប់ការបង្កើតមន្ទីរពេទ្យបង្អែក<br>- កំណត់ស្តង់ដារគុណភាព មគ្គុទេសក៍គ្លីនិក និងសេចក្តីណែនាំបច្ចេកទេស | - រៀបចំផែនការសកម្មភាព និងថវិកាសម្រាប់គ្រប់គ្រង និងផ្តល់សេវានៃមន្ទីរសុខាភិបាលស្របតាមគោលនយោបាយ ផែនការ យុទ្ធសាស្ត្រ វិធាន លក្ខណៈវិនិច្ឆ័យ និងស្តង់ដារដែលបានកំណត់។ | | - ឆ្នាំ២០១៧៖ ប្រគល់មុខងារនេះទៅឱ្យរដ្ឋបាលរាជធានីភ្នំពេញ រដ្ឋបាលខេត្តបាត់ដំបង និងរដ្ឋបាលខេត្តកំពត<br>- ឆ្នាំ២០២០៖ ប្រគល់មុខងារទៅឱ្យរដ្ឋបាលខេត្តដែលនៅសេសសល់ទាំងអស់ទូទាំងប្រទេស |
| ១.២ | ការរៀបចំកម្មវិធីជាតិ | - រៀបចំកម្មវិធីជាតិការពារជំងឺគ្រប់ប្រភេទ<br>- ស្រាវជ្រាវស្វែងរកការអភិវឌ្ឍវិស័យសុខាភិបាល | - អនុវត្តកម្មវិធីការពារជំងឺគ្រប់ប្រភេទ កម្មវិធីបង្ការថែទាំ វេជ្ជសាស្ត្រ និងអន្តរាគមន៍នៃកម្មវិធីជាតិនានាតាមរយៈការអភិវឌ្ឍ ការអនុវត្ត និងការពិនិត្យ | | |

| ល.រ | មុខងារ/កិច្ចការ | រដ្ឋបាលថ្នាក់ជាតិ | រដ្ឋបាលថ្នាក់រាជធានី ខេត្ត | រដ្ឋបាលថ្នាក់ក្រុងស្រុក | ដំណាក់កាលផ្ទេរ |
|---|---|---|---|---|---|
| | | - រៀបចំកម្មវិធីបង្ការ និងការថែទាំវេជ្ជសាស្ត្រ ដើម្បីបន្ថយមូលហេតុនៃជំងឺ<br>- ផ្ដល់ការគាំទ្រដល់ការផ្ដល់សេវាបង្ការ ពិនិត្យ ព្យាបាល និងថែទាំ។ | តាមដានផែនការប្រតិបត្តិក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ | | |
| ១.៣ | ការគ្រប់គ្រងគ្រូពេទ្យ បុគ្គ-លិកជំនាញសុខាភិបាល និងបុគ្គលិកផ្សេងទៀត | - កសាងផែនការអភិវឌ្ឍន៍ធនធានមនុស្សវិស័យសុខាភិបាល<br>- កំណត់និយាម ចំនួន និងមុខតំណែងវិជ្ជាជីវៈរបស់បុគ្គលិកសម្រាប់មន្ទីរពេទ្យ<br>- ជ្រើសរើស និងបែងចែកគ្រូពេទ្យ បុគ្គលិកជំនាញសុខាភិបាល<br>- បណ្ដុះបណ្ដាលមូលដ្ឋាន បណ្ដុះបណ្ដាលបន្តឬក្នុងពេលកំពុងបម្រើការងារ។ | - កសាងផែនការតម្រូវការបុគ្គលិក<br>- គ្រប់គ្រងគ្រូពេទ្យ បុគ្គលិកជំនាញសុខាភិបាល និងបុគ្គលិកផ្សេងទៀត<br>- លើកសំណើជ្រើសរើសគ្រូពេទ្យ និងបុគ្គលិកជំនាញសុខាភិបាល<br>- ជ្រើសរើសបុគ្គលិកដែលមិនមែនជាគ្រូពេទ្យ និងមិនមែនជាបុគ្គលិកជំនាញសុខាភិបាល។ | | |
| ១.៤ | ការគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធ ថវិកា ទ្រព្យសម្បត្តិ និងភស្តុភារ (ឱសថ បរិក្ខារពេទ្យ និងឧបករណ៍អមវេជ្ជសាស្ត្រ) | - កំណត់និយាមសម្រាប់ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធសុខាភិបាល<br>- កំណត់និមាប័នកម្មគំរូនៃការសាងសង់មន្ទីរពេទ្យ<br>- កំណត់បញ្ជីស្តង់ដារឱសថសារវ័ន្ត បរិក្ខារពេទ្យ ឧបករណ៍អមវេជ្ជសាស្ត្រ សម្រាប់មន្ទីរពេទ្យខេត្ត<br>- លទ្ធកម្ម និងបែងចែកមធ្យោបាយ | - លទ្ធកម្មលើការសាងសង់ ជួសជុល និងការថែទាំហេដ្ឋារចនាសម្ព័ន្ធនៃមន្ទីរពេទ្យខេត្ត<br>- លទ្ធកម្មលើមធ្យោបាយ សម្ភារ ឱសថ បរិក្ខារពេទ្យ និងឧបករណ៍អមវេជ្ជសាស្ត្រ និងការជួសជុល ថែទាំបរិក្ខារពេទ្យ ឧបករណ៍អមវេជ្ជសាស្ត្រនៃមន្ទីរពេទ្យខេត្តតាមការអនុញ្ញាតពីក្រសួង | | |

| ល.រ | មុខងារ/កិច្ចការ | រដ្ឋបាលថ្នាក់ជាតិ | រដ្ឋបាលថ្នាក់រាជធានី ខេត្ត | រដ្ឋបាលថ្នាក់ក្រុងស្រុក | ដំណាក់កាលផ្ទេរ |
|---|---|---|---|---|---|
| | | សម្ភារ ឱសថ បរិក្ខារពេទ្យ និងឧប-<br>ករណ៍អមវេជ្ជសាស្ត្រ<br>- កៀរគរធនធានសម្រាប់អភិវឌ្ឍវិស័យ<br>សុខាភិបាល។<br>- សម្រេចលើការបង្កើតមន្ទីរពេទ្យខេត្ត | - គ្រប់គ្រង ចាត់ចែងទ្រព្យសម្បត្តិ<br>មធ្យោបាយ សម្ភារ ឱសថ បរិក្ខារពេទ្យ<br>និងឧបករណ៍អមវេជ្ជសាស្ត្រ<br>- គ្រប់គ្រង ចាត់ចែងថវិកាសម្រាប់<br>ប្រតិបត្តិការនៃមន្ទីរសុខាភិបាល<br>- លើកសំណើបង្កើតមន្ទីរពេទ្យខេត្ត។ | | |
| ១.៥ | ការផ្តល់លិខិតអនុញ្ញាត<br>បើកមន្ទីរពេទ្យ មន្ទីរពហុ<br>ព្យាបាល និងគ្លីនិកឯក<br>ជន | - កំណត់ស្តង់ដារអប្បបរមាសម្រាប់<br>ដំណើរការមន្ទីរពេទ្យ មន្ទីរពហុព្យា<br>បាល និងគ្លីនិកឯកជន<br>- កំណត់លក្ខណៈវិនិច្ឆ័យ នីតិវិធីគោល<br>ការណ៍ណែនាំ សម្រាប់ការបង្កើត<br>មន្ទីរពេទ្យ មន្ទីរពហុព្យាបាល និងគ្លីនី<br>កឯកជន<br>- ចេញលិខិតអនុញ្ញាតសម្រាប់បង្កើត<br>មន្ទីរពេទ្យឯកជន។ | - ផ្តល់ការអនុញ្ញាតបើកមន្ទីរពហុ<br>ព្យាបាល គ្លីនិកឯកជន និងឱសថស្ថាន<br>- ផ្តល់សេវានានាដែលមន្ទីរសុខាភិបាល<br>បាន និងកំពុងផ្តល់។ | | |
| ១.៦ | ការគាំទ្រ ការតាមដាន<br>ត្រួតពិនិត្យ និងវាយតម្លៃ | - តាមដានត្រួតពិនិត្យលើការគ្រប់គ្រង<br>និងការផ្តល់សេវាសុខាភិបាលដែល<br>អនុវត្តដោយរដ្ឋបាលរាជធានី ខេត្ត<br>- វាយតម្លៃលើគុណភាពនៃការផ្តល់<br>សេវាសុខាភិបាលនៅរាជធានី ខេត្ត<br>- ផ្តល់ការគាំទ្របច្ចេកទេសក្នុងការ<br>កសាងផែនការប្រតិបត្តិ និងផែនការ | - រៀបចំរបាយការណ៍វឌ្ឍនភាព និង<br>របាយការណ៍ហិរញ្ញវត្ថុនៃការអនុវត្ត<br>មុខងារគ្រប់គ្រងមន្ទីរសុខាភិបាល<br>- គាំទ្រ តាមដាន ត្រួតពិនិត្យគុណភាព<br>សេវាសុខាភិបាលដែលផ្តល់ដោយ<br>មន្ទីរពេទ្យ មន្ទីរពហុព្យាបាល និង<br>គ្លីនិកឯកជន។ | | |

| ល.រ | មុខងារ/កិច្ចការ | រដ្ឋបាលថ្នាក់ជាតិ | រដ្ឋបាលថ្នាក់រាជធានី ខេត្ត | រដ្ឋបាលថ្នាក់ក្រុងស្រុក | ដំណាក់កាលផ្ទេរ |
|---|---|---|---|---|---|
| | | ថវិកាដោយរាប់បញ្ចូលទាំងអន្តរាគមន៍សុខភាពសាធារណៈនៃកម្មវិធីសុខភាពនានា។ | | | |
| ២ | **ការគ្រប់គ្រង និងការផ្តល់សេវានៃការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ** | | | | |
| ២.១. | រៀបចំគោលនយោបាយ និងផែនការ | - រៀបចំគោលនយោបាយជាតិវិស័យសុខាភិបាល<br>- អភិវឌ្ឍផែនការ និងយុទ្ធសាស្ត្រសម្រាប់វិស័យសុខាភិបាល<br>- អភិវឌ្ឍវិធាន និយតកម្ម និងគោលការណ៍ណែនាំ ដើម្បីបង្កើនគុណភាពសេវាសុខភាពជាអតិបរមាទាំងនៅផ្នែកសាធារណៈ និងឯកជន<br>- កំណត់លក្ខណៈវិនិច្ឆ័យសម្រាប់ការបង្កើតមន្ទីរពេទ្យបង្អែក មណ្ឌលសុខភាព និងប៉ុស្តិ៍សុខភាព<br>- កំណត់ស្តង់ដារគុណភាព មគ្គុទេសក៍គ្លីនិក និងសេចក្តីណែនាំបច្ចេកទេសផ្សេងៗ។ | - ផ្តល់ការគាំទ្របច្ចេកទេសក្នុងការរៀបចំផែនការសកម្មភាព និងថវិកាសម្រាប់អនុវត្តមុខងារគ្រប់គ្រង និងការផ្តល់សេវានៃការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ | - រៀបចំផែនការសកម្មភាព និងថវិកាសម្រាប់គ្រប់គ្រង និងផ្តល់សេវានៃការិយាល័យសុខាភិបាលស្រុកប្រតិបត្តិស្របតាមគោលនយោបាយ ផែនការយុទ្ធសាស្ត្រ វិធាន លក្ខណៈវិនិច្ឆ័យ និងស្តង់ដារដែលកំណត់ដោយក្រសួងសុខាភិបាល។ | - ឆ្នាំ២០១៧៖ ប្រគល់មុខងារនេះទៅឱ្យរដ្ឋបាលរាជធានីភ្នំពេញ រដ្ឋបាលក្រុង ស្រុកទាំងអស់ក្នុងខេត្តបាត់ដំបង និងរដ្ឋបាល ក្រុង ស្រុកទាំងអស់ក្នុងខេត្តកំពត<br>- ឆ្នាំ២០២០៖ ប្រគល់មុខងារទៅឱ្យរដ្ឋបាលក្រុងស្រុកទាំងអស់ក្នុងខេត្តដែលនៅសេសសល់ទាំងអស់ទូទាំងប្រទេស |
| ២.២ | ការរៀបចំកម្មវិធីជាតិ | - រៀបចំកម្មវិធីជាតិការពារជំងឺគ្រប់ប្រភេទ<br>- ស្រាវជ្រាវស្វែងរកការអភិវឌ្ឍវិស័យ | - ផ្តល់ការគាំទ្រដល់រដ្ឋបាលក្រុង ស្រុកក្នុងការអនុវត្តកម្មវិធីជាតិ | - អនុវត្តកម្មវិធីជាតិការពារជំងឺគ្រប់ប្រភេទ កម្មវិធីបង្ការថែទាំវេជ្ជសាស្ត្រ និងអន្តរាគមន៍សុខភាពសាធារណៈ | |

| ល.រ | មុខងារ/កិច្ចការ | រដ្ឋបាលថ្នាក់ជាតិ | រដ្ឋបាលថ្នាក់រាជធានី ខេត្ត | រដ្ឋបាលថ្នាក់ក្រុងស្រុក | ដំណាក់កាលផ្ទេរ |
| --- | --- | --- | --- | --- | --- |
| | | សុខាភិបាល<br>- រៀបចំកម្មវិធីបង្ការ និងការថែទាំវេជ្ជសាស្ត្រ ដើម្បីបន្ថយមូលហេតុនៃជំងឺ<br>- ផ្តល់ការគាំទ្រដល់ការផ្តល់សេវាបង្ការ ពិនិត្យនិងព្យាបាលថែទាំ។ | | នៃកម្មវិធីជាតិនានា តាមរយៈការអភិវឌ្ឍ ការអនុវត្ត និងការពិនិត្យតាមដានផែនការប្រតិបត្តិក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ | |
| ២.៣ | ការគ្រប់គ្រងគ្រូពេទ្យ បុគ្គលិកជំនាញសុខាភិបាល និងបុគ្គលិកផ្សេងទៀត | - កសាងផែនការអភិវឌ្ឍន៍ធនធានមនុស្សវិស័យសុខាភិបាល<br>- កំណត់និយាម ចំនួន និងមុខតំណែងវិជ្ជាជីវៈរបស់បុគ្គលិកសម្រាប់មន្ទីរពេទ្យបង្អែកស្រុក មណ្ឌលសុខភាព និងប៉ុស្តិ៍សុខភាព<br>- ជ្រើសរើស និងបែងចែកគ្រូពេទ្យ បុគ្គលិកជំនាញសុខាភិបាល<br>- បណ្តុះបណ្តាលមូលដ្ឋាន បណ្តុះបណ្តាលបន្តក្នុងពេលបម្រើការងារ។ | - ផ្តល់ការគាំទ្រដល់ការរៀបចំផែនការបុគ្គលិក ការអភិវឌ្ឍសមត្ថភាពដល់បុគ្គលិក មន្ទីរពេទ្យបង្អែកស្រុក មណ្ឌលសុខភាព និងប៉ុស្តិ៍សុខភាព | - កសាងផែនការតម្រូវការបុគ្គលិក<br>- គ្រប់គ្រងគ្រូពេទ្យ បុគ្គលិកជំនាញសុខាភិបាល និងបុគ្គលិកផ្សេងទៀត<br>- លើកសំណើជ្រើសរើសគ្រូពេទ្យ និងបុគ្គលិកជំនាញសុខាភិបាល<br>- ជ្រើសរើសបុគ្គលិកដែលមិនមែនជាគ្រូពេទ្យ និងមិនមែនជាបុគ្គលិកជំនាញសុខាភិបាល។ | |
| ២.៤ | ការគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធ ថវិកា ទ្រព្យសម្បត្តិ និងភស្តុភារ (ឱសថ បរិក្ខារពេទ្យ និងឧបករណ៍អមវេជ្ជសាស្ត្រ) | - កំណត់និយាមសម្រាប់ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធសុខាភិបាល<br>- កំណត់និមាប័នកម្មគំរូនៃការសាងសង់មន្ទីរពេទ្យបង្អែកក្រុង ស្រុក ខណ្ឌ មណ្ឌលសុខភាព និងប៉ុស្តិ៍សុខភាព<br>- កំណត់បញ្ជីស្តង់ដារឱសថសារវន្ត បរិក្ខារពេទ្យ ឧបករណ៍អមវេជ្ជសាស្ត្រ | | - លទ្ធកម្មលើការសាងសង់ ជួសជុល និងការថែទាំហេដ្ឋារចនាសម្ព័ន្ធនៃមន្ទីរពេទ្យបង្អែកក្រុង ស្រុក ខណ្ឌ មណ្ឌលសុខភាព និងប៉ុស្តិ៍សុខភាព<br>- លទ្ធកម្មលើមធ្យោបាយ សម្ភារ ឱសថ បរិក្ខារពេទ្យ និងឧបករណ៍អមវេជ្ជសាស្ត្រ និងការជួសជុល | |

| ល.រ | មុខងារ/កិច្ចការ | រដ្ឋបាលថ្នាក់ជាតិ | រដ្ឋបាលថ្នាក់រាជធានី ខេត្ត | រដ្ឋបាលថ្នាក់ក្រុងស្រុក | ដំណាក់កាលផ្ទេរ |
|---|---|---|---|---|---|
| | | សម្រាប់មន្ទីរពេទ្យបង្អែកក្រុង ស្រុក ខណ្ឌ មណ្ឌលសុខភាព និងប៉ុស្តិ៍សុខភាព<br>- លទ្ធកម្ម និងបែងចែកមធ្យោបាយ សម្ភារ ឱសថ បរិក្ខារពេទ្យ និងឧបករណ៍អមវេជ្ជសាស្ត្រ<br>- កៀរគរធនធានសម្រាប់អភិវឌ្ឍវិស័យសុខាភិបាល<br>- សម្រេចលើការបង្កើតមន្ទីរពេទ្យបង្អែកក្រុង ស្រុក ខណ្ឌ និងមណ្ឌលសុខភាព ។ | | ថែទាំបរិក្ខារពេទ្យ ឧបករណ៍អមវេជ្ជសាស្ត្រនៃមន្ទីរពេទ្យបង្អែកក្រុង ស្រុក ខណ្ឌ មណ្ឌលសុខភាព និងប៉ុស្តិ៍សុខភាពតាមការកំណត់<br>- គ្រប់គ្រង ចាត់ចែងទ្រព្យសម្បត្តិ មធ្យោបាយ សម្ភារ ឱសថ បរិក្ខារពេទ្យ និងឧបករណ៍អមវេជ្ជសាស្ត្រ<br>- គ្រប់គ្រងចាត់ចែងថវិកាសម្រាប់ប្រតិបត្តិការនៃមន្ទីរពេទ្យបង្អែកក្រុង ស្រុក ខណ្ឌ មណ្ឌលសុខភាព និងប៉ុស្តិ៍សុខភាព<br>- លើកសំណើបង្កើតមន្ទីរពេទ្យបង្អែកក្រុង ស្រុក ខណ្ឌ និងមណ្ឌលសុខភាព<br>- បង្កើតប៉ុស្តិ៍សុខភាព។ | |
| ២.៥ | ផ្តល់លិខិតអនុញ្ញាត បើកបន្ទប់ពិនិត្យ ពិគ្រោះយោបល់ និងព្យាបាល (បន្ទប់ពិនិត្យស្ត្រីមានផ្ទៃពោះ ព្យាបាលដោយចលនា ថែទាំជម្ងឺ ព្យាបាលមាត់ធ្មេញ និង | - កំណត់ស្តង់ដារអប្បបរមាសម្រាប់ដំណើរការបន្ទប់ពិនិត្យ ពិគ្រោះយោបល់ និងព្យាបាល និងឱសថស្ថានរង<br>- កំណត់លក្ខណៈវិនិច្ឆ័យ នីតិវិធី គោលការណ៍ណែនាំសម្រាប់ដំណើរការបន្ទប់ពិនិត្យ ពិគ្រោះយោបល់ និង | | - ផ្តល់ការអនុញ្ញាតបើកបន្ទប់ពិនិត្យ ពិគ្រោះយោបល់ និងព្យាបាល និងឱសថស្ថានរង។ | |

| ល.រ | មុខងារ/កិច្ចការ | រដ្ឋបាលថ្នាក់ជាតិ | រដ្ឋបាលថ្នាក់រាជធានី ខេត្ត | រដ្ឋបាលថ្នាក់ក្រុងស្រុក | ដំណាក់កាលផ្ទេរ |
|---|---|---|---|---|---|
| | ពិគ្រោះជម្ងឺទូទៅ) និង ឱសថស្ថានរង | ព្យាបាល និងឱសថស្ថានរង។ | | | |
| ២.៦ | ការគាំទ្រ ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ | - តាមដានត្រួតពិនិត្យលើការគ្រប់គ្រង និងការផ្តល់សេវាសុខាភិបាលដែលអនុវត្តដោយរដ្ឋបាលរាជធានី ក្រុង ស្រុក<br>- វាយតម្លៃលើគុណភាពនៃការផ្តល់សេវាសុខាភិបាលនៅរាជធានី ក្រុង ស្រុក<br>- ផ្តល់ការគាំទ្របច្ចេកទេសក្នុងការកសាងផែនការប្រតិបត្តិ និងផែនការថវិកា ដោយរាប់បញ្ចូលទាំងអន្តរាគមន៍សុខភាពសាធារណៈនៃកម្មវិធីសុខភាពនានា។ | - តាមដាន ត្រួតពិនិត្យ និងគាំទ្រផ្នែកបច្ចេកទេសដល់រដ្ឋបាលក្រុង ស្រុក។ | - រៀបចំរបាយការណ៍វឌ្ឍនភាពនិងរបាយការណ៍ហិរញ្ញវត្ថុនៃការអនុវត្តមុខងារគ្រប់គ្រងការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ<br>- តាមដានត្រួតពិនិត្យគុណភាព សេវាសុខាភិបាលដែលផ្តល់ដោយ វិស័យឯកជនក្នុងក្របខណ្ឌនៃសមត្ថកិច្ចរបស់ខ្លួន។ | |

## II. បញ្ជីមុខងារក្នុងវិស័យសាធារណការ និងដឹកជញ្ជូនដែលត្រូវផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ

| ល.រ | មុខងារ/កិច្ចការ | រដ្ឋបាលថ្នាក់ជាតិ | រដ្ឋបាលខេត្ត | រដ្ឋបាលរាជធានី ក្រុង ស្រុក | ដំណាក់កាលផ្ទេរ |
|---|---|---|---|---|---|
| ១.ផ្នែកសាធារណការ | | | | | |
| ១.១ | **ការគ្រប់គ្រងដីចំណីផ្លូវជាតិ និងផ្លូវខេត្តដែលស្ថិតនៅក្នុងទីរួមខេត្ត ក្រុង និងស្រុក** | - រៀបចំគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត<br>- កំណត់បទដ្ឋាន និងសេចក្ដីណែនាំបច្ចេកទេស<br>- ផ្សព្វផ្សាយគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋាន និងបណ្ដុះបណ្ដាលបទដ្ឋានបច្ចេកទេស<br>- គាំទ្រ ត្រួតពិនិត្យ តាមដាន និងវាយតម្លៃការអនុវត្ត | | - គ្រប់គ្រងដីចំណីផ្លូវជាតិ និងផ្លូវខេត្តដែលស្ថិតនៅក្នុងរាជធានី និងក្នុងទីប្រជុំជនក្រុង ស្រុកក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ | - ២០១៧ ប្រតិភូកម្មទៅឱ្យរដ្ឋបាលរាជធានី ក្រុង ស្រុក ទាំងអស់ |
| ១.២ | **ការសាងសង់ ការជួសជុល ការថែទាំផ្លូវរាជធានី ផ្លូវក្រុង និងផ្លូវទីប្រជុំជននានាក្នុងខេត្ត** | - រៀបចំគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋាន<br>- រៀបចំផែនការមេសម្រាប់ការអភិវឌ្ឍន៍បណ្ដាញផ្លូវ ស្ពាន និងលូ<br>- កំណត់បទដ្ឋាន និងសេចក្ដីណែនាំបច្ចេកទេស<br>- ផ្សព្វផ្សាយគោលនយោបាយច្បាប់ និងលិខិតបទដ្ឋាន និងបណ្ដុះបណ្ដាលបទដ្ឋានបច្ចេកទេស<br>- គាំទ្រ ត្រួតពិនិត្យ តាមដាន និងវាយតម្លៃការអនុវត្ត | - សាងសង់ ជួសជុលនិងថែទាំផ្លូវក្នុងរាជធានី ផ្លូវក្រុង ផ្លូវទីប្រជុំជននានាក្នុងស្រុក ដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន | | - ប្រគល់ទៅឱ្យរដ្ឋបាលរាជធានី ខេត្ត |

| | | | | | |
|---|---|---|---|---|---|
| ១.៣ | ការគ្រប់គ្រង ការត្រួតពិនិត្យសេវាលាងរថយន្ត ទោចក្រយានយន្ត | - រៀបចំលិខិតបទដ្ឋានគតិយុត្ត<br>- កំណត់បទដ្ឋានបច្ចេកទេស និងគោលការណ៍ណែនាំ<br>- ផ្សព្វផ្សាយ និងបណ្តុះបណ្តាលបច្ចេកទេស<br>- គាំទ្រ ត្រួតពិនិត្យ តាមដាន និងវាយតម្លៃការអនុវត្ត | | - គ្រប់គ្រង ត្រួតពិនិត្យសេវាលាងរថយន្ត ទោចក្រយានយន្តក្នុងដែនសមត្ថកិច្ចរបស់ខ្លួន | - ឆ្នាំ២០១៧ ប្រគល់ទៅឱ្យរាជធានី ក្រុង ស្រុកទាំងអស់ |
| **ល.រ** | **មុខងារ/កិច្ចការ** | **រដ្ឋបាលថ្នាក់ជាតិ** | **រដ្ឋបាលរាជធានី ខេត្ត** | **រដ្ឋបាលក្រុង ស្រុក ខណ្ឌ** | **ដំណាក់កាលផ្ទេរ** |
| **២.ផ្នែកដឹកជញ្ជូន** | | | | | |
| ២.១ | **ការចុះបញ្ជីយានយន្ត ទោចក្រយានយន្ត ត្រីចក្រយានយន្ត ម៉ូតូកង់៤ ដែលជាកម្មសិទ្ធិឯកជន** | - រៀបចំគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋាន<br>- កំណត់បទដ្ឋានបច្ចេកទេស<br>- ផ្សព្វផ្សាយគោលនយោបាយ ច្បាប់ លិខិតបទដ្ឋាន និងបណ្តុះបណ្តាលបទដ្ឋានបច្ចេកទេស<br>- គាំទ្រ និងតាមដាន ត្រួតពិនិត្យ ណែនាំ និងសម្របសម្រួលប្រតិបត្តិការផ្តល់សេវាចុះបញ្ជីយានយន្ត<br>- គ្រប់គ្រងស្ថិតិ ទិន្នន័យ ប្រព័ន្ធស្វ័យប្រវត្តិកម្មចុះបញ្ជីយានយន្ត<br>- គ្រប់គ្រងការផលិតផ្លាកលេខ និងបណ្ណសម្គាល់យានយន្ត<br>- រក្សាទុកឯកសារចុះបញ្ជីយានយន្ត | - ចុះបញ្ជី ផ្តល់ផ្លាកលេខ បណ្ណសម្គាល់រថយន្តតាមប្រព័ន្ធស្វ័យប្រវត្តិកម្មចុះបញ្ជីរថយន្ត | - ចុះបញ្ជី ផ្តល់ផ្លាកលេខ បណ្ណសម្គាល់ទោចក្រយានយន្ត ត្រីចក្រយានយន្ត ម៉ូតូកង់៤តាមប្រព័ន្ធស្វ័យប្រវត្តិកម្មចុះបញ្ជីយានយន្ត | - ឆ្នាំ២០១៧ ធ្វើប្រតិភូកម្មទៅឱ្យរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌទូទាំងប្រទេស |

| | | | | | |
|---|---|---|---|---|---|
| ២.២ | ការប្រឡងយកប័ណ្ណបើកបរយានយន្ត និង ការប្តូរ ការពន្យារ ការធ្វើទុតិយតា និងតតិយតា ប័ណ្ណបើកបរយានយន្ត (លើកលែងជនបរទេស) | - រៀបចំលិខិតបទដ្ឋានគតិយុត្ត និង គោលការណ៍ណែនាំ<br>- កំណត់បទដ្ឋានបច្ចេកទេស<br>- ផ្សព្វផ្សាយលិខិតបទដ្ឋាន គោលការណ៍ណែនាំ និងបណ្តុះបណ្តាលបទដ្ឋានបច្ចេកទេស<br>- គាំទ្រ និងតាមដាន ត្រួតពិនិត្យ | - រៀបចំ និងគ្រប់គ្រងការប្រឡងយកប័ណ្ណបើកបរយានយន្ត និងប្តូរ ពន្យារ ទុតិយតា តតិយតា (ទោចក្រយានយន្តប្រភេទ ក រថយន្តប្រភេទ ខ ) | | - ឆ្នាំ២០១៧ ធ្វើប្រតិភូកម្មទៅឱ្យរដ្ឋបាលរាជធានី ខេត្តទូទាំងប្រទេស |
| ២.៣ | ការគ្រប់គ្រងយានដ្ឋានជួសជុល កែច្នៃ តម្លើងយានយន្ត (ប្រគល់ ) | - រៀបចំគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋាន<br>- កំណត់បទដ្ឋានបច្ចេកទេស<br>- ផ្សព្វផ្សាយគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋាន បណ្តុះបណ្តាលបទដ្ឋានបច្ចេកទេស<br>- គាំទ្រ តាមដានត្រួតពិនិត្យការអនុវត្ត<br>- គ្រប់គ្រងស្ថិតិយានដ្ឋានជួសជុល កែច្នៃ តម្លើងយានយន្ត | - ចុះបញ្ជី និងផ្តល់លិខិតអនុញ្ញាតធ្វើអាជីវកម្ម យានដ្ឋានជួសជុល កែច្នៃ តម្លើងរថយន្ត<br>- គ្រប់គ្រងស្ថិតិយានដ្ឋានជួសជុល កែច្នៃ តម្លើងរថយន្ត | - ចុះបញ្ជី និងផ្តល់លិខិតអនុញ្ញាតធ្វើអាជីវកម្មយានដ្ឋានជួសជុល កែច្នៃ តម្លើងទោចក្រយានយន្ត<br>- គ្រប់គ្រងស្ថិតិយានដ្ឋានជួសជុល កែច្នៃ តម្លើងទោចក្រយានយន្តគ្រប់ប្រភេទ | - ឆ្នាំ២០១៧ ប្រគល់ទៅឱ្យរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌទូទាំងប្រទេស |
| ២.៤ | ការត្រួតពិនិត្យលក្ខណៈបច្ចេកទេសទោចក្រយានយន្តសណ្តោងរ៉ឺម៉ក និងត្រីចក្រយានយន្ត | - រៀបចំលិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំ<br>- កំណត់បទដ្ឋានបច្ចេកទេស<br>- ផ្សព្វផ្សាយលិខិតបទដ្ឋាន គោលការណ៍ណែនាំ និងបណ្តុះបណ្តាលបទដ្ឋានបច្ចេកទេស<br>- គាំទ្រ តាមដានត្រួតពិនិត្យការអនុវត្ត | - | - រៀបចំ និងគ្រប់គ្រងការត្រួតពិនិត្យបច្ចេកទេសទោចក្រយានយន្តសណ្តោងរ៉ឺម៉ក និងត្រីចក្រយានយន្ត | - ឆ្នាំ២០១៧ ប្រគល់ទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌទូទាំងប្រទេស |

| | | | | | |
|---|---|---|---|---|---|
| ២.៥ | **ការគ្រប់គ្រង និងការចុះបញ្ជីជលយាន និងដរចម្លង** | - រៀបចំគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋាន<br>- កំណត់បទដ្ឋានបច្ចេកទេស<br>- ផ្សព្វផ្សាយគោលនយោបាយ ច្បាប់ លិខិតបទដ្ឋាន និងបណ្តុះបណ្តាលបទដ្ឋានបច្ចេកទេស<br>- គាំទ្រ និងតាមដាន ត្រួតពិនិត្យ ណែនាំ និងសម្របសម្រួលប្រតិបត្តិការផ្តល់សេវាចុះបញ្ជីជលយាន និងដរចម្លង<br>- គ្រប់គ្រងស្ថិតិជលយាន និងដរចម្លង | - ការចុះបញ្ជី ផ្តល់ប័ណ្ណសម្គាល់ និងត្រួតពិនិត្យបច្ចេកទេសជលយាន<br>- គ្រប់គ្រង និងផ្តល់លិខិតអនុញ្ញាតដរចម្លងអន្តរក្រុង ស្រុក | - គ្រប់គ្រងនិងផ្តល់លិខិតអនុញ្ញាតដរចម្លងក្នុងក្រុងស្រុក | - ឆ្នាំ២០១៧ ប្រគល់ទៅឱ្យរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុកទូទាំងប្រទេស |

## III.បញ្ជីមុខងារក្នុងវិស័យបរិស្ថាន និងកសិកម្មដែលត្រូវផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ

| ល.រ | មុខងារ/កិច្ចការ | រដ្ឋបាលថ្នាក់ជាតិ | រដ្ឋបាលថ្នាក់រាជធានី ខេត្ត | រដ្ឋបាលថ្នាក់ក្រុងស្រុក | ដំណាក់កាលផ្ទេរ |
|---|---|---|---|---|---|
| ១ | ការការពារ និងអភិរក្សធម្មជាតិ និងអភិវឌ្ឍន៍សហគមន៍ | - រៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រជាតិ<br>- រៀបចំលិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំបច្ចេកទេស<br>- សិក្សាស្រាវជ្រាវដើម្បីការការពារអភិរក្ស និងអភិវឌ្ឍប្រកបដោយចីរភាព<br>- ពង្រឹងសមត្ថភាពស្ថាប័ន និងធនធានមនុស្សថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ<br>- សម្រេចកំណត់តំបន់សម្រាប់បង្កើតសហគមន៍តំបន់ការពារធម្មជាតិ<br>- ស្វែងរកការគាំទ្រផ្នែកបច្ចេកទេស និងកៀគរធនធានហិរញ្ញវត្ថុទាំងកម្រិតជាតិ និងអន្តរជាតិសម្រាប់ការការពារ និងអភិរក្សធម្មជាតិ<br>- តាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយ ផែនការយុទ្ធសាស្ត្រជាតិ និងលិខិតបទដ្ឋានគតិយុត្ត<br>- ពង្រឹងប្រសិទ្ធភាពនៃការអនុវត្តនៅថ្នាក់ក្រោមជាតិ | - ផ្សព្វផ្សាយច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំស្តីពីការការពារ និងអភិរក្ស ធម្មជាតិ<br>- គ្រប់គ្រង អភិវឌ្ឍន៍ និងអភិរក្សតំបន់ការពារធម្មជាតិដែលមានលក្ខណៈអន្តរស្រុកក្នុងខេត្ត (អាចបង្កើត គណៈកម្មាធិការអន្តរខេត្តក្នុងការរៀបចំផែនការរួមសម្រាប់គ្រប់គ្រងអភិវឌ្ឍន៍ និងអភិរក្ស តំបន់ការពារធម្មជាតិដែលមានលក្ខណៈ អន្តរខេត្ត)<br>- សម្របសម្រួលក្នុងការបង្កើត និងការអភិវឌ្ឍសហគមន៍តំបន់ការពារធម្មជាតិ<br>- សម្រេចលើកិច្ចព្រមព្រៀង និងផែនការគ្រប់គ្រង សហគមន៍តំបន់ការពារធម្មជាតិក្រោយ | - ផ្សព្វផ្សាយច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំស្តីពីការការពារ និងអភិរក្សធម្មជាតិ<br>- គ្រប់គ្រង អភិវឌ្ឍន៍ និងអភិរក្សតំបន់ការពារធម្មជាតិក្នុងក្រុងស្រុក<br>- ពង្រឹងសមត្ថភាពសហគមន៍តំបន់ការពារធម្មជាតិ<br>- សម្របសម្រួលបង្កើត គ្រប់គ្រង និងគាំទ្រសហគមន៍តំបន់ការពារធម្មជាតិ | |

| ល.រ | មុខងារ/កិច្ចការ | រដ្ឋបាលថ្នាក់ជាតិ | រដ្ឋបាលថ្នាក់រាជធានី ខេត្ត | រដ្ឋបាលថ្នាក់ក្រុងស្រុក | ដំណាក់កាលផ្ទេរ |
|---|---|---|---|---|---|
| | | - ពិនិត្យសម្រេចក្នុងការផ្តល់សិទ្ធប្រើប្រាស់ដីនៅក្នុងតំបន់ការពារ | មានការឯកភាពពីថ្នាក់ជាតិ<br>- សម្របសម្រួល និងគ្រប់គ្រងដីតំបន់ការពារដែលត្រូវបានផ្តល់សិទ្ធិប្រើប្រាស់ដោយថ្នាក់ជាតិ | | |
| ២ | កិច្ចគាំពារបរិស្ថាន | - រៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រជាតិ<br>- រៀបចំលិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំបច្ចេកទេស<br>- ពង្រឹងសមត្ថភាពស្ថាប័ន និងអភិវឌ្ឍន៍ធនធានមនុស្សថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ<br>- សិក្សាស្រាវជ្រាវ និងគ្រប់គ្រងមន្ទីរពិសោធន៍កម្រិតជាតិ<br>- ដឹកនាំសម្របសម្រួលជាមួយដៃគូអភិវឌ្ឍន៍ វិស័យឯកជន វិស័យសាធារណៈ ក្នុងការកៀរគធនធានហិរញ្ញវត្ថុ មធ្យោបាយ និងសម្ភារៈសម្រាប់គាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិ<br>- គាំទ្រ និងសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោម | - ផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្ត<br>- សម្របសម្រួលជាមួយអង្គភាពពាក់ព័ន្ធដើម្បីជំរុញ និងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន<br>- គ្រប់គ្រងសំរាម សំណល់រឹង (ចំពោះរដ្ឋបាលរាជធានី)<br>- គ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ (ចំពោះរដ្ឋបាលរាជធានី)<br>- សម្របសម្រួលជាមួយអង្គភាពពាក់ព័ន្ធដើម្បីជំរុញ និងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងប្រព័ន្ធលូ ប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ | - ផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្ត<br>- គ្រប់គ្រងសំរាម សំណល់រឹង<br>- គ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់<br>- ផ្តល់កិច្ចសហការ ត្រួតពិនិត្យការបំពុលគ្រប់ប្រភេទ<br>- ចូលរួមអង្កេតតាមដានការអនុវត្តគម្រោង វិនិយោគដែលបានធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម<br>- ចូលរួមផ្សព្វផ្សាយកិច្ចសន្យាការពារបរិស្ថាន<br>- ផ្សព្វផ្សាយដល់សាធារណជននៅតាមមូលដ្ឋានពីគម្រោងអភិវឌ្ឍន៍វិនិយោគ | |

| ល.រ | មុខងារ/កិច្ចការ | រដ្ឋបាលថ្នាក់ជាតិ | រដ្ឋបាលថ្នាក់រាជធានី ខេត្ត | រដ្ឋបាលថ្នាក់ក្រុងស្រុក | ដំណាក់កាលផ្ទេរ |
|---|---|---|---|---|---|
| | | ជាតិ ក្នុងការលើកកម្ពស់ការអប់រំក្នុង និងក្រៅប្រព័ន្ធ និងការផ្សព្វផ្សាយអំពីកិច្ចគាំពារបរិស្ថាន<br>- តាមដាន និងត្រួតពិនិត្យគុណភាពទឹក ដី ខ្យល់ក្នុងកម្រិតជាតិ<br>- វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងអង្កេតតាមដានលើគម្រោងអភិវឌ្ឍន៍កម្រិតជាតិ<br>- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងលិខិតបទដ្ឋានគតិយុត្ត<br>- ពង្រឹងប្រសិទ្ធភាពការអនុវត្តនៅថ្នាក់ក្រោមជាតិ | - គ្រប់គ្រងត្រួតពិនិត្យគុណភាពទឹក ដី ខ្យល់ និងគ្រប់ប្រភពបំពុលក្នុងដែនសមត្ថកិច្ចខេត្តតាមគោលការណ៍ណែនាំ<br>- សិក្សាស្រាវជ្រាវ និងគ្រប់គ្រងមន្ទីរពិសោធន៍កម្រិតខេត្ត<br>- គ្រប់គ្រងទិន្នន័យគ្រប់ប្រភេទពាក់ព័ន្ធនឹងការបំពុលបរិស្ថានក្នុងខេត្ត និងផ្តល់ព័ត៌មានទិន្នន័យមកថ្នាក់ជាតិ<br>- កៀរគរថវិកាគាំទ្រពីប្រភពនានា<br>- វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងអង្កេតតាមដានលើគម្រោងវិនិយោគក្នុងដែនសមត្ថកិច្ចខេត្ត និងកិច្ចសន្យាការពារបរិស្ថាន | | |
| ៣ | **ការអភិវឌ្ឍន៍ដោយចីរភាព** | - រៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងលិខិតបទដ្ឋានគតិយុត្ត<br>- ណែនាំ សម្របសម្រួលការអនុវត្ត និងវាយតម្លៃគោលនយោបាយ ផែនការ | - បញ្ជ្រាបការអភិវឌ្ឍដោយចីរភាពទៅក្នុងផែនការសកម្មភាព កម្មវិធី និងគម្រោងពាក់ព័ន្ធរាជធានីខេត្ត | - ចូលរួម និងលើកកម្ពស់ការអ[illegible] ការបណ្តុះបណ្តាល ការផ្ស[illegible] ការងារពាក់ព័ន្ធ នឹងការអភិវឌ្ឍ[illegible] ដោយចីរភា( សេដ្ឋកិច្ចបៃតង | |

| ល.រ | មុខងារ/កិច្ចការ | រដ្ឋបាលថ្នាក់ជាតិ | រដ្ឋបាលថ្នាក់រាជធានី ខេត្ត | រដ្ឋបាលថ្នាក់ក្រុងស្រុក | ដំណាក់កាលផ្ទេរ |
|---|---|---|---|---|---|
| | | យុទ្ធសាស្ត្រ បទដ្ឋានគតិយុត្ត កម្មវិធី និងគម្រោងនានាពាក់ព័ន្ធការអភិវឌ្ឍ ដោយចីរភាព<br>- លើកកំពស់ការបញ្ជ្រាបការអភិវឌ្ឍ ដោយចីរភាពទៅក្នុងគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព បទដ្ឋានគតិយុត្ត កម្មវិធី និងគម្រោងពាក់ព័ន្ធនានាដោយសហការ ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ<br>- រៀបចំបង្កើតមូលនិធិ កៀរគរធនធាន និងគ្រប់គ្រងការអនុវត្តគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព បទដ្ឋានគតិយុត្ត កម្មវិធីនិងគម្រោងនានាពាក់ព័ន្ធការអភិវឌ្ឍ ដោយចីរភាព<br>- កសាងនិងពង្រឹងកិច្ចសហប្រតិបត្តិការ ជាមួយដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល វិស័យឯកជន គ្រឹះស្ថានស្រាវជ្រាវ និងអ្នកពាក់ព័ន្ធផ្សេងទៀត<br>- ជំរុញ និងលើកកម្ពស់ការសិក្សាស្រាវ | - ផ្តល់ធាតុចូលទាក់ទងការអភិវឌ្ឍ ដោយចីរភាពពីថ្នាក់រាជធានី ខេត្តទៅក្នុងការងាររបស់ ក.ជ.អ.ច. និងក្រុមការងារបច្ចេកទេស កណ្តាលនីមួយៗ<br>- សម្របសម្រួល និងតាមដានការអនុវត្តគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព បទដ្ឋានគតិយុត្ត កម្មវិធី និងគម្រោងនានាពាក់ព័ន្ធការអភិវឌ្ឍដោយចីរភាព<br>- អប់រំ បណ្តុះបណ្តាល ផ្សព្វផ្សាយការងារពាក់ព័ន្ធនឹងការអភិវឌ្ឍដោយចីរភាព (សេដ្ឋកិច្ចបៃតង ការប្រែប្រួលអាកាសធាតុ ការអភិរក្ស ជីវចម្រុះនិងជីវសុវត្ថិភាព វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា)<br>- ចូលរួមក្នុងការប្រមូលទិន្នន័យ ការកំណត់អាទិភាព និងការ | ការប្រែប្រួលអាកាសធាតុ ការអភិរក្សជីវចម្រុះ និងជីវសុវត្ថិភាព វិទ្យាសាស្ត្រនិងបច្ចេកវិទ្យ)<br>- ចូលរួមសហការ និងសម្របសម្រួល ការអនុវត្តការងារ ពាក់ព័ន្ធនឹងសេដ្ឋកិច្ចបៃតង ការប្រែប្រួលអាកាសធាតុ ការ អភិរក្សជីវចម្រុះ និងជីវសុវត្ថិភាព វិទ្យាសាស្ត្រ បច្ចេកវិទ្យា<br>- បញ្ជ្រាបការបន្សាំ និងភាពធន់នឹងការប្រែប្រួលអាកាសធាតុ ទៅក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគថ្នាក់ក្រុង ស្រុក ឃុំ សង្កាត់<br>- ប្រមូលចងក្រង និងគ្រប់គ្រងវិភាគព័ត៌មាន ទិន្នន័យស្តីពី[illegible] រងគ្រោះដោយសារគ្រោះធម្មជាតិមិនប្រក្រតី និងទិន្នន័យពាក់ព័ន្ធផ្សេងៗ | |

| ល.រ | មុខងារ/កិច្ចការ | រដ្ឋបាលថ្នាក់ជាតិ | រដ្ឋបាលថ្នាក់រាជធានី ខេត្ត | រដ្ឋបាលថ្នាក់ក្រុងស្រុក | ដំណាក់កាលផ្ទេរ |
|---|---|---|---|---|---|
| | | ជ្រាវ ការអប់រំ ការបណ្តុះបណ្តាល ការផ្លាស់ប្តូរបច្ចេកវិទ្យា ការគ្រប់គ្រងចំណេះដឹង ការផ្សព្វផ្សាយពាក់ព័ន្ធនឹងការអភិវឌ្ឍដោយចីរភាព<br>- គ្រប់គ្រង ដឹកនាំ និងសម្របសម្រួលការងារសេដ្ឋកិច្ចបៃតង ការប្រែប្រួលអាកាសធាតុ ការអភិរក្សជីវចម្រុះ និងជីវសុវត្ថិភាព វិទ្យាសាស្ត្រ បច្ចេកវិទ្យា<br>- បំពេញមុខងារជាស្ថាប័នជាតិបង្គោលនៃអនុសញ្ញា ពិធីសារ និងកិច្ចព្រមព្រៀងអន្តរជាតិពាក់ព័ន្ធនឹងការអភិវឌ្ឍដោយចីរភាព (សេដ្ឋកិច្ចបៃតង ការប្រែប្រួលអាកាសធាតុ ជីវចម្រុះ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា)។ | ពិគ្រោះយោបល់<br>- សម្របសម្រួលកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ និងភាគីពាក់ព័ន្ធ | | |
| ៤ | **ការអប់រំ និងផ្សព្វផ្សាយបរិស្ថាន** | - រៀបចំគោលនយោបាយ យុទ្ធសាស្ត្រ លិខិតបទដ្ឋានគតិយុត្ត ផែនការ និងកម្មវិធីនានាពាក់ព័ន្ធការអប់រំនិងផ្សព្វផ្សាយព័ត៌មានបរិស្ថាន<br>- ប្រមូល វិភាគ ចងក្រង និងគ្រប់គ្រងទិន្នន័យបរិស្ថាន និងធនធានធម្មជាតិ រួម | - សម្របសម្រួល និងដឹកនាំការអនុវត្តកម្មវិធីសាលាមេត្រីបរិស្ថាន ( Eco School ) នៅតាមសាលារៀនទាំងថ្នាក់បឋម និងមធ្យមសិក្សា<br>- សម្របសម្រួល និងដឹកនាំការ | | |

| ល.រ | មុខងារ/កិច្ចការ | រដ្ឋបាលថ្នាក់ជាតិ | រដ្ឋបាលថ្នាក់រាជធានី ខេត្ត | រដ្ឋបាលថ្នាក់ក្រុងស្រុក | ដំណាក់កាលផ្ទេរ |
|---|---|---|---|---|---|
| | | ទាំងប្រព័ន្ធទិន្នន័យឯកទេស<br>- ផលិតនិងផ្សព្វផ្សាយព័ត៌មានស្តីពីសកម្មភាពពាក់ព័ន្ធកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការប្រើប្រាស់ធនធានធម្មជាតិឱ្យបានសមស្រប និងមាននិរន្តរភាព និងការរស់នៅដោយចីរភាព<br>- លើកកម្ពស់ការអប់រំ និងការយល់ដឹងពីបរិស្ថានដល់សាធារណជន<br>- រៀបចំនិងចាត់ចែងពិធីនានាជាសាធារណៈ និង សកម្មភាពផ្សព្វផ្សាយបរិស្ថាន<br>- លើកទឹកចិត្តឱ្យមានសកម្មភាព ដែលមានមេត្រីភាពជាមួយបរិស្ថាន<br>- រៀបចំ និងគ្រប់គ្រងប្រព័ន្ធផ្សព្វផ្សាយព័ត៌មានបរិស្ថាន<br>- សម្របសម្រួលជាមួយអង្គភាពនានាក្រោមឱវាទក្រសួង ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការ និងបង្កើនប្រសិទ្ធភាពការងារគ្រប់គ្រងទិន្នន័យបរិស្ថាន និងការអប់រំនិងផ្សព្វផ្សាយបរិស្ថាន. | កសាងសមត្ថភាពស្ថាប័ន និងធនធានមនុស្សតាមរយៈការបើកវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងការធ្វើបទបង្ហាញផ្សេងៗ<br>- សម្របសម្រួល និងដឹកនាំការផ្សព្វផ្សាយព័ត៌មានបរិស្ថាននៅថ្នាក់ក្រោមជាតិ និងចូលរួមផ្តល់ព័ត៌មាន និងទិន្នន័យបរិស្ថានដល់ថ្នាក់ជាតិ<br>- សម្របសម្រួល និងដឹកនាំការរៀបចំព្រឹត្តិការណ៍បរិស្ថាននានា<br>- ជំរុញសកម្មភាពមេត្រីភាពបរិស្ថានជាមួយអង្គភាពនានា | | |

| ល.រ | មុខងារ/កិច្ចការ | រដ្ឋបាលថ្នាក់ជាតិ | រដ្ឋបាលថ្នាក់ខេត្ត | រដ្ឋបាលថ្នាក់ក្រុងស្រុក | ដំណាក់កាលផ្ទេរ |
|---|---|---|---|---|---|
| ៥ | ការគ្រប់គ្រងព្រៃឈើ | – គោលនយោបាយជាតិ ផែនការយុទ្ធសាស្ត្រជាតិ បទដ្ឋានបច្ចេកទេស<br>– អភិវឌ្ឍ និងកសាងសមត្ថភាព<br>– អធិការកិច្ច ត្រួតពិនិត្យ តាមដាន និងវាយតម្លៃ<br>– កំណត់តំបន់ ប្រភេទ ព្រំប្រទល់ ផែនទីព្រៃឈើ<br>– ចុះបញ្ជិកាសម្បត្តិព្រៃឈើអចិន្ត្រៃយ៍<br>– សិទ្ធិសម្រេចផ្តល់ព្រៃផ្តល់ផល<br>– ការកែប្រែប្រភេទព្រៃឈើ<br>– កំណត់កូតា និងសិទ្ធសម្រេច នាំចេញនាំចូល<br>– សិទ្ធិសម្រេចបង្កើតឧស្សាហកម្ម រោងចក្រអារឈើ<br>– ការចុះទិដ្ឋាការនាំចេញនាំចូល លិខិតអនុញ្ញាតនាំចេញនាំចូលក្រៅប្រទេស | – គ្រប់គ្រង អភិវឌ្ឍ និងអភិរក្សព្រៃឈើក្នុងដែនសមត្ថកិច្ចរបស់ខ្លួន<br>– រៀបចំផែនការគ្រប់គ្រងព្រៃឈើក្នុងដែនសមត្ថកិច្ចរបស់ខ្លួន<br>– ចេញលិខិតកំណត់កូតាអនុញ្ញាតប្រមូលផល អនុផលព្រៃឈើសម្រាប់សហគមន៍មូលដ្ឋាននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន<br>– ចាត់វិធានការសមស្របដើម្បីស្រាវជ្រាវ ទប់ស្កាត់ និងបង្ក្រាបរាល់បទល្មើសព្រៃឈើនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន<br>– អប់រំផ្សព្វផ្សាយដើម្បីលើកកម្ពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋអំពីសារៈសំខាន់នៃការគ្រប់គ្រង ការថែរក្សាការពារ និងការអភិវឌ្ឍធនធានព្រៃឈើ<br>– សហប្រតិបត្តិការជាមួយអង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ និងសប្បុរសជន ក្នុងការគ្រប់គ្រង ការថែរក្សាការពារ និងការអភិវឌ្ឍវិស័យព្រៃឈើក្នុងដែនសមត្ថកិច្ច | – រៀបចំ បង្កើត ពង្រឹង និងគាំទ្រសហគមន៍ក្នុងការគ្រប់គ្រងធនធានព្រៃឈើដែលបង្កើតដោយសហគមន៍<br>– ចេញលិខិតអនុញ្ញាតប្រមូលផលអនុផលព្រៃឈើសម្រាប់សហគមន៍មូលដ្ឋាននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន<br>– អប់រំផ្សព្វផ្សាយដើម្បីលើកកម្ពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋអំពីសារៈសំខាន់នៃការគ្រប់គ្រង ការថែរក្សាការពារ និងការអភិវឌ្ឍធនធានព្រៃឈើ នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន<br>– ធ្វើការដាំដុះព្រៃឈើឡើងវិញនៅលើដីព្រៃរេចរិល និងដីព្រៃទំនេរក្នុងដែនសមត្ថកិច្ចរបស់ខ្លួន | |

| ល.រ | មុខងារ/កិច្ចការ | រដ្ឋបាលថ្នាក់ជាតិ | រដ្ឋបាលថ្នាក់ខេត្ត | រដ្ឋបាលថ្នាក់ក្រុងស្រុក | ដំណាក់កាលផ្ទេរ |
|---|---|---|---|---|---|
| | | | របស់ខ្លួន<br>– ត្រួតពិនិត្យការធ្វើអាជីវកម្ម ការដឹកជញ្ជូន កន្លែងសន្និធិ ទីតាំងលក់ មូលដ្ឋានឧស្សាហកម្ម រោងចក្រ សិប្បកម្មកែច្នៃ និងឡគ្រប់ប្រភេទ ដែលប្រើប្រាស់ផល អនុផលព្រៃឈើនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន<br>– ត្រួតពិនិត្យអាជ្ញាប័ណ្ណ លិខិតអនុញ្ញាត និងឯកសារផ្សេងទៀត ដែលតម្រូវឱ្យត្រួតពិនិត្យនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ។ | | |
| ៦ | ការគ្រប់គ្រងជលផល | – រៀបចំគោលនយោបាយវិស័យជលផលជាតិ<br>– រៀបចំផែនយុទ្ធសាស្ត្រវិស័យជលផលជាតិ<br>– រៀបចំ ពិនិត្យ និងកែសម្រួលច្បាប់ លិខិតបទដ្ឋានគតិយុត្ត<br>– អភិវឌ្ឍន៍ និងពង្រឹងសមត្ថភាពនៃការគ្រប់គ្រងធនធានជលផល<br>– កំណត់បទដ្ឋានបច្ចេកទេស និងបទបញ្ជាបច្ចេកទេសនៃវិស័យជលផល<br>– កំណត់ទម្រង់បែបបទនៃលិខិត និងនីតិវិធី | – គ្រប់គ្រង អភិរក្ស និងអភិវឌ្ឍធនធានជលផលក្នុងដែនសមត្ថកិច្ចរបស់ខ្លួន<br>– ចាត់វិធានការស្រាវជ្រាវ ទប់ស្កាត់ និងបង្ក្រាបបទល្មើស ជលផលនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន<br>– អនុញ្ញាតឱ្យបង្កើត និងចុះកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ក្នុងការគ្រប់គ្រងធនធានជលផលដោយសហគមន៍ | – រៀបចំ បង្កើត ពង្រឹង និងគាំទ្រសហគមន៍ក្នុងការគ្រប់គ្រងធនធានជលផលដោយសហគមន៍<br>– ស្រាវជ្រាវ ទប់ស្កាត់ និងបង្ក្រាបបទល្មើស ជលផលក្នុងដែនសមត្ថកិច្ចរបស់ខ្លួន<br>– អប់រំផ្សព្វផ្សាយដល់ប្រជាពលរដ្ឋអំពីសារៈសំខាន់នៃការគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍធនធានជលផលប្រកបដោយនិរន្តរភាពក្នុងដែន | |

| ល.រ | មុខងារ/កិច្ចការ | រដ្ឋបាលថ្នាក់ជាតិ | រដ្ឋបាលថ្នាក់ខេត្ត | រដ្ឋបាលថ្នាក់ក្រុងស្រុក | ដំណាក់កាលផ្ទេរ |
|---|---|---|---|---|---|
| | | សម្រាប់ប្រើប្រាស់ជាផ្លូវការក្នុងវិស័យជលផល<br>– សម្របសម្រួលការអនុវត្តសកម្មភាពជលផល<br>– សហប្រតិបត្តការជាតិ និងអន្តរជាតិលើវិស័យជលផល<br>– រៀបចំឯកសារសម្រាប់ចុះបញ្ជីទទួលស្គាល់សហគមន៍នេសាទ<br>– អនុញ្ញាតឱ្យបង្កើតទីតាំងកែច្នៃផល ផលិតផលជលផលទ្រង់ទ្រាយឧស្សាហកម្ម<br>– អនុញ្ញាតឱ្យបង្កើតកំពង់ផែនេសាទ<br>– អនុញ្ញាតការធ្វើអាជីវកម្មនេសាទ ឬវារីវប្បកម្មចំពោះជនបរទេស<br>– អនុញ្ញាតធ្វើវារីវប្បកម្មទ្រង់ទ្រាយធំ (តាមប្រកាសរបស់ក្រសួងកសិកម្ម)<br>– អនុញ្ញាតធ្វើអាជីវកម្មនេសាទជាលក្ខណៈឧស្សាហកម្មនៅទឹកសាប និងនេសាទសមុទ្រចំពោះទូកដែលមានកំលាំងម៉ាស៊ីនចាប់ពី៥០សេសឡើង<br>– អនុញ្ញាតការនាំចូលនូវពូជវារីសត្វ ឬវារីរុក្ខជាតិគ្រប់ប្រភេទពីបរទេស<br>– អនុញ្ញាតការនាំចេញ ការនាំចូលនូវផល | – អប់រំផ្សព្វផ្សាយដល់ប្រជាពលរដ្ឋអំពីសារៈសំខាន់នៃការគ្រប់គ្រងការអភិរក្ស និងការអភិវឌ្ឍធនធានជលផលប្រកបដោយនិរន្តរភាព<br>– ចេញលិខិតអនុញ្ញាតក្នុងការអាជីវកម្មនេសាទ ការធ្វើវារីវប្បកម្ម និងកែច្នៃជាលក្ខណៈសិប្បកម្មដែលស្ថិតនៅក្នុងសមត្ថកិច្ចរបស់ខ្លួន<br>– ចេញលិខិតអនុញ្ញាតការធ្វើសន្និធិសិប្បកម្មកែច្នៃ ការបង្កើតផែត្រី ការទិញ និងការលក់ផល ផលិតផលជលផល ដែលស្ថិតនៅក្នុងសមត្ថកិច្ចរបស់ខ្លួន<br>– ចេញលិខិតអនុញ្ញាតក្នុងការដឹកជញ្ជូនផល ផលិតផលជលផលជាលក្ខណៈពាណិជ្ជកម្មទៅតាមគោលដៅនៅប្រទេសកម្ពុជា<br>– សហប្រតិបត្តិការជាមួយអង្គការដៃគូអភិវឌ្ឍន៍ និងសប្បុរសជន ក្នុងការគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍធនធានជលផលក្នុងដែនសមត្ថកិច្ចរបស់ខ្លួន | សមត្ថកិច្ចរបស់ខ្លួន។ | |

| ល.រ | មុខងារ/កិច្ចការ | រដ្ឋបាលថ្នាក់ជាតិ | រដ្ឋបាលថ្នាក់ខេត្ត | រដ្ឋបាលថ្នាក់ក្រុងស្រុក | ដំណាក់កាលផ្ទេរ |
|---|---|---|---|---|---|
| | | ផលិតផលជលផល<br>– រៀបចំឯកសារ និងអប់រំផ្សព្វផ្សាយដល់ប្រជាពលរដ្ឋអំពីសារៈសំខាន់នៃការគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍធនធានជលផល<br>– គាំទ្របច្ចេកទេសដល់រដ្ឋបាលថ្នាក់ក្រោមជាតិ និងសហគមន៍ក្នុងការគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍធនធានជលផល<br>– ត្រួតពិនិត្យ តាមដាន និងវាយតម្លៃទៅលើការគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍធនធានជលផល និងវារីវប្បកម្ម<br>– អនុវត្ត និងចាត់វិធានការក្នុងករណីចាំបាច់លើការគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍធនធានជលផល និងវារីវប្បកម្ម<br>– ត្រួតពិនិត្យ និងវិភាគសុវត្ថិភាព និងគុណភាពផលិតផលជលផល<br>– សិក្សា ស្រាវជ្រាវ សេដ្ឋកិច្ច សង្គមជលផល ជីវសាស្ត្រ អេកូឡូស៊ី ឧបករណ៍នេសាទ និងផលស្តុកធនធានជលផល និងវារីវប្បកម្ម | – ត្រួតពិនិត្យការធ្វើអាជីវកម្មនេសាទ និងផល ផលិតផលជលផលក្នុងដែនសមត្ថកិច្ចរបស់ខ្លួន<br>– ត្រួតពិនិត្យការដឹកជញ្ជូនផល ផលិតផលជលផលតាមមធ្យោបាយដឹកជញ្ជូននានាក្នុងដែនសមត្ថកិច្ចរបស់ខ្លួន<br>– ត្រួតពិនិត្យអាជ្ញាប័ណ្ណ លិខិតអនុញ្ញាត និងឯកសារផ្សេងទៀតដែលតម្រូវឱ្យត្រួតពិនិត្យ នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន<br>– គ្រប់គ្រងស្ថិតិ ជលផល មធ្យោបាយ និងសម្ភារជលផល ប្រជានេសាទក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ | | |

| ល.រ | មុខងារ/កិច្ចការ | រដ្ឋបាលថ្នាក់ជាតិ | រដ្ឋបាលថ្នាក់ខេត្ត | រដ្ឋបាលថ្នាក់ក្រុងស្រុក | ផ្សេងៗ |
|---|---|---|---|---|---|
| ៧ | **ការគ្រប់គ្រងការងារក្សេត្រសាស្ត្រ និងការគ្រប់គ្រងដី សម្រាប់ការដាំដុះ** | – រៀបចំគោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត គោលការណ៍បច្ចេកទេសកសិកម្ម<br>– កសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្តសម្រាប់កសិដ្ឋាន ស្ថានីយ៍ និងមណ្ឌលអភិវឌ្ឍកសិកម្ម ដើម្បីបម្រើឱ្យការងារផលិតពូជ ពិសោធន៍ ស្រាវជ្រាវ ធ្វើពិពិធកម្មកសិកម្ម និងផ្ទេរបច្ចេកវិទ្យាពាក់ព័ន្ធការអភិវឌ្ឍផលិតកម្មកសិកម្ម<br>– គ្រប់គ្រងមន្ទីរពិសោធន៍ជាតិកសិកម្ម សម្រាប់ការងារវិភាគយថាប្រភេទជាតុ និងមីក្រូសរីរាង្គនៅក្នុងសមាសភាគដី វុទ្ធជាតិដី និងថ្នាំកសិកម្ម។<br>– សិក្សា ស្រាវជ្រាវនិងរៀបចំបទដ្ឋានបច្ចេកទេសសម្រាប់លើកកម្ពស់ការថែរក្សា និងកែលំអគុណភាពដី បច្ចេកទេសគ្រប់គ្រងជីវជាតិដី<br>– សិក្សាចងក្រងទិន្នន័យមូលដ្ឋានអំពីដីកសិកម្ម តំបន់ដាំដុះ ចំណាត់ថ្នាក់ដីដំណាំស្រូវ សាកវប្បកម្ម ដំណាំឧស្សាហកម្ម និងដំណាំរួមផ្សំ<br>– ចងក្រងទិន្នន័យមូលដ្ឋានអំពីដីកសិកម្ម បម្រែបម្រួលការប្រើប្រាស់ដីកសិកម្ម កំណត់ | – ផ្សព្វផ្សាយអំពីវិធានការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ សម្រាប់ធានានិរន្តរភាពប្រព័ន្ធកសិកម្ម<br>– រៀបចំ និងអនុវត្តផែនការសកម្មភាពជួយសង្គ្រោះគ្រោះមហន្តរាយកសិកម្មក្នុងដែនសមត្ថកិច្ចរបស់ ខ្លួន<br>– ផ្សព្វផ្សាយពូជស្រូវ សាកវប្បកម្ម ដំណាំឧស្សាហកម្ម និងដំណាំរួមផ្សំដែលមានសក្តានុពល ផ្តល់ទិន្នផលខ្ពស់ និងស្របតាមប្រព័ន្ធក្សេត្របរិស្ថាន<br>– អង្កេត វិភាគទិន្នន័យ និងរៀបចំវេទិកាផ្លាស់ប្តូរបទពិសោធន៍ស្តីពីបច្ចេកទេស បញ្ហាប្រឈម និងដំណោះស្រាយពាក់ព័ន្ធនឹងផលិតកម្មដំណាំស្រូវ សាកវប្បកម្មដំណាំឧស្សាហកម្ម និងដំណាំរួមផ្សំ<br>– ចាត់វិធានការទប់ស្កាត់ហានិភ័យនានាពាក់ព័ន្ធនឹងការរាតត្បាតសមាសភាពចង្រៃផ្សេងៗលើ | – ផ្សព្វផ្សាយអំពីបច្ចេកទេសពាក់ព័ន្ធនឹងការអភិវឌ្ឍកសិកម្មដំណាំ<br>– ជំរុញការអនុវត្តបច្ចេកទេសក្នុងការថែរក្សា ការកែលម្អគុណភាពដី និងកំចាត់ជីវជាតិដី<br>– ជំរុញការអនុវត្តវិធានការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ សម្រាប់ធានានិរន្តរភាពប្រព័ន្ធកសិកម្ម<br>– ផ្សព្វផ្សាយ និងជំរុញការប្រើប្រាស់ពូជស្រូវ សាកវប្បកម្ម ដំណាំឧស្សាហកម្ម និងដំណាំរួមផ្សំដែលមានសក្តានុពល និងផ្តល់ទិន្នផលខ្ពស់<br>– ផ្សព្វផ្សាយ និងចាត់វិធានការគ្រប់គ្រង និងកំចាត់សមាសភាពចង្រៃលើដំណាំក្នុងដែនសមត្ថកិច្ចរបស់ខ្លួន<br>– ចាត់វិធានការទប់ស្កាត់ហានិភ័យនានាពាក់ព័ន្ធនឹងការរាតត្បាតសមាសភាពចង្រៃផ្សេងៗលើដំណាំ<br>– ផ្សព្វផ្សាយកសិកម្ម(ពូជដំណាំ | ក្រសួងឯកភាព ប៉ុន្តែស្នើកែសម្រួលមួយចំនួន |

| ល.រ | មុខងារ/កិច្ចការ | រដ្ឋបាលថ្នាក់ជាតិ | រដ្ឋបាលថ្នាក់ខេត្ត | រដ្ឋបាលថ្នាក់ក្រុងស្រុក | ដំណាក់កាលផ្ទេរ |
|---|---|---|---|---|---|
| | | តំបន់ដាំដុះ កំណត់តំបន់កសិកម្ម និងធ្វើចំណាត់ថ្នាក់ដីសមស្របសម្រាប់ដំណាំ<br>- សិក្សាស្រាវជ្រាវ អភិវឌ្ឍ ផលិត និងផ្សព្វផ្សាយពូជស្រូវ សាកវប្បកម្ម ដំណាំឧស្សាហកម្ម និងដំណាំរួមផ្សំដែលមានសក្តានុពល ផ្តល់ទិន្នផលខ្ពស់ និងស្របតាមប្រព័ន្ធក្សេត្របរិស្ថាន<br>- សិក្សាស្រាវជ្រាវ និងរៀបចំយុទ្ធសាស្ត្រអំពីវិធានការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ និងកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ សម្រាប់ធានានិរន្តរភាពប្រព័ន្ធកសិកម្ម<br>- សិក្សាពិសោធន៍ ស្រាវជ្រាវ ចងក្រងអត្តបទបច្ចេកទេសការពារដំណាំ លក្ខណៈជីវសាស្ត្រ សមាសភាពចង្រៃ វិធានការទប់ស្កាត់ និងកម្ចាត់<br>- រៀបចំស្តង់ដារ គុណភាព ផលិតផលដំណាំប្រព័ន្ធគ្រប់គ្រងធានាសុវត្ថិភាពផលិតផលកសិកម្ម<br>- រៀបចំបទដ្ឋានបច្ចេកទេសសម្រាប់ការពារដំណាំ និងអនុវត្តការត្រួតពិនិត្យភូតគាមអនាម័យលើទំនិញនាំចេញនាំចូល ឆ្លង | ដំណាំ<br>- ជំរុញការផ្សព្វផ្សាយកសិកម្ម (ពូជដំណាំ បច្ចេកទេសដាំដុះ ដី ជី ការការពារ និងកំចាត់សត្វចង្រៃ ទីផ្សារផលិតផលកសិកម្ម...)<br>- គាំទ្រ និងចងក្រងសហគមន៍កសិកម្មក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ | បច្ចេកទេសដាំដុះ ដី ជី ការការពារ កំចាត់សត្វចង្រៃ និងទីផ្សារផលិតផលកសិកម្ម...)<br>- អភិវឌ្ឍសហគមន៍កសិកម្មក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ | |

| ល.រ | មុខងារ/ភារកិច្ច | រដ្ឋបាលថ្នាក់ជាតិ | រដ្ឋបាលថ្នាក់ខេត្ត | រដ្ឋបាលថ្នាក់ក្រុង ស្រុក | ដំណាក់កាលផ្ទេរ |
|---|---|---|---|---|---|
| | | កាត់ និងចាត់វិធានការភូតគាមអនាម័យ<br>– រៀបចំប្រព័ន្ធ មធ្យោបាយ និងវិធីសាស្ត្រផ្សព្វផ្សាយកសិកម្ម<br>– រៀបចំបទដ្ឋានបច្ចេកទេសសម្រាប់លើកកម្ពស់ការអភិវឌ្ឍសហគមន៍កសិកម្ម<br>– សម្របសម្រួលជាមួយក្រសួង ស្ថាប័ន និងផ្នែកឯកជនដើម្បីពង្រីកទីផ្សារផលិតផលកសិកម្ម | | | |
| ៨ | **ការគ្រប់គ្រងដំណាំកសិ-ឧស្សាហកម្ម** | – រៀបចំបទដ្ឋានបច្ចេកទេសសម្រាប់កែច្នៃផលិតផលកសិកម្ម និងផលិតកម្មកសិកម្មតាមកិច្ចសន្យា<br>– ពង្រឹង តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តរបស់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច<br>– គ្រប់គ្រងទិន្នន័យសហគ្រាសកសិ-ឧស្សាហកម្ម និងចងក្រងសហគមន៍កសិ-ឧស្សាហកម្មទូទាំងប្រទេស<br>– រៀបចំបទដ្ឋានបច្ចេកទេសសម្រាប់ការប្រមូលផល ការដឹកជញ្ជូន ការវេចខ្ចប់ ការសម្ងួត និងការរក្សាទុកផលិតផលកែច្នៃ<br>– រៀបចំបទដ្ឋានបច្ចេកទេសសម្រាប់ការគ្រប់គ្រង និងប្រើប្រាស់សំណល់កសិកម្ម | – បណ្តុះបណ្តាលអំពីបច្ចេកទេសកែច្នៃផលិតផលកសិកម្ម និងផលិតកម្មកសិកម្មតាមកិច្ចសន្យា<br>– តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តរបស់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចក្នុងដែនសមត្ថកិច្ចរបស់ខ្លួន<br>– កសាងមណ្ឌលបច្ចេកទេសកសិ-ឧស្សាហកម្ម<br>– គ្រប់គ្រងទិន្នន័យសហគ្រាសកសិ-ឧស្សាហកម្ម និងចងក្រងសហគមន៍កសិ-ឧស្សាហកម្មក្នុងដែនសមត្ថកិច្ចរបស់ខ្លួន<br>– ផ្សព្វផ្សាយ និងបណ្តុះបណ្តាល | – ផ្សព្វផ្សាយបច្ចេកទេសប្រមូលផល ការដឹកជញ្ជូន ការវេចខ្ចប់ ការសម្ងួត និងការរក្សាទុកផលិតផលកែច្នៃ<br>– ជំរុញការអភិវឌ្ឍសហគ្រាសកសិ-ឧស្សាហកម្ម និងចងក្រងសហគមន៍កសិ-ឧស្សាហកម្មក្នុងដែនសមត្ថកិច្ចរបស់ខ្លួន<br>– គ្រប់គ្រង និងប្រើប្រាស់សំណល់កសិកម្ម និង កសិ-ឧស្សាហកម្មគ្រប់ប្រភេទ និងកែច្នៃសំណល់កសិកម្មជាប្រភពថាមពលជីធម្មជាតិ និងចំណីសត្វ<br>– ពង្រឹងការអនុវត្តបច្ចេកវិទ្យាសមស្របដែលមានការបំភាយឧស្ម័នផ្ទះ | |

| ល.រ | មុខងារ/កិច្ចការ | រដ្ឋបាលថ្នាក់ជាតិ | រដ្ឋបាលថ្នាក់ខេត្ត | រដ្ឋបាលថ្នាក់ក្រុងស្រុក | ដំណាក់កាលផ្ទេរ |
|---|---|---|---|---|---|
| | | និងកសិ-ឧស្សាហកម្មគ្រប់ប្រភេទ និងកែច្នៃសំណល់កសិកម្មជាប្រភពថាមពលជីធម្មជាតិ និងចំណីសត្វ<br>– ពង្រឹងការអនុវត្តបច្ចេកវិទ្យាសមស្របដែលមានការបំភាយឧស្ម័នផ្ទះកញ្ចក់កម្រិតទាប | បច្ចេកទេសការប្រមូលផល ការដឹកជញ្ជូន ការវេចខ្ចប់ ការសម្ងួត និងការរក្សាទុកផលិតផលកែច្នៃ<br>– គ្រប់គ្រង និងប្រើប្រាស់សំណល់កសិកម្ម និងកសិ-ឧស្សាហកម្មគ្រប់ប្រភេទ និងកែច្នៃសំណល់កសិកម្មជាប្រភពថាមពលជីធម្មជាតិ និងចំណីសត្វ<br>– ផ្សព្វផ្សាយ និងជំរុញការអនុវត្តបច្ចេកវិទ្យាសមស្របដែលមានការបំភាយឧស្ម័នផ្ទះកញ្ចក់ | កញ្ចក់កម្រិតទាប។ | |
| ៩ | ការគ្រប់គ្រងសុខភាពសត្វ និងផលិតកម្មសត្វ | – រៀបចំគោលនយោបាយជាតិ និងរៀបចំផែនការយុទ្ធសាស្ត្រជាតិផែនការជាតិសម្រាប់ការអភិវឌ្ឍវិស័យសុខភាពសត្វ និងផលិតកម្មសត្វ<br>– បទដ្ឋានគតិយុត្ត បទដ្ឋានបច្ចេកទេស<br>– ផ្តល់ការគាំទ្របច្ចេកទេស និងអភិវឌ្ឍសមត្ថភាព<br>– តាមដាន ត្រួតពិនិត្យ វាយតម្លៃ និងអធិការកិច្ច<br>– កំណត់ប្រភេទជម្ងឺឆ្លង តំបន់ដែលមានជម្ងឺឆ្លង ប្រកាសដាក់ភាពអាសន្ន និងរំសាយ | – រៀបចំ និងអនុវត្តផែនការសកម្មភាពសម្រាប់ការអភិវឌ្ឍវិស័យសុខភាពសត្វ និងផលិតកម្មសត្វក្នុងដែនសមត្ថកិច្ចរបស់ខ្លួន<br>– ចាត់វិធានការបង្ការ និងទប់ស្កាត់ជម្ងឺឆ្លងនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន<br>– ផ្សព្វផ្សាយពូជសត្វដល់កសិករ និងអាជីវករចិញ្ចឹមសត្វក្នុងដែនសមត្ថកិច្ចរបស់ខ្លួន<br>– អនុញ្ញាតលើការបង្កើតទីកន្លែងផ | – រៀបចំ និងអនុវត្តផែនការសកម្មភាពសម្រាប់ការអភិវឌ្ឍវិស័យសុខភាពសត្វ និងផលិតកម្មសត្វក្នុងដែនសមត្ថកិច្ចរបស់ខ្លួន<br>– ចាត់វិធានការបង្ការ និងទប់ស្កាត់ជម្ងឺឆ្លងនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន<br>– ផ្សព្វផ្សាយពូជសត្វដល់កសិករ និងអាជីវករចិញ្ចឹមសត្វក្នុងដែនសមត្ថកិច្ចរបស់ខ្លួន<br>– អនុញ្ញាតលើការបង្កើតទីកន្លែងផល | |

| លរ | មុខងារ/កិច្ចការ | រដ្ឋបាលថ្នាក់ជាតិ | រដ្ឋបាលថ្នាក់ខេត្ត | រដ្ឋបាលថ្នាក់ក្រុងស្រុក | ដំណាក់កាលផ្ទេរ |
|---|---|---|---|---|---|
| | | ភាពអាសន្ននៃជម្ងឺឆ្លង វិធានការដើម្បីបង្ការ និងទប់ស្កាត់ជម្ងឺឆ្លង<br>– សិក្សាស្រាវជ្រាវ បង្កើត និងធ្វើបច្ចុប្បន្នភាពពូជសត្វ ក្នុងគោលបំណងអភិរក្សពូជសត្វក្នុងស្រុក និងបង្កើតពូជសត្វថ្មី ចុះបញ្ជីពូជសត្វ<br>– អនុញ្ញាតលើការនាំចេញ និងនាំចូលពូជសត្វទាំងក្នុងរូបភាពជាសត្វរស់ និងរូបធាតុសេនេទិក<br>– កំណត់បទដ្ឋានបច្ចេកទេសសម្រាប់ការបង្កើតទីកន្លែងផលិត និងសន្និធិផលិតផលសត្វ និងទីកន្លែងផលិត ចែកចាយ និងលក់បសុឱសថ និងវត្ថុធាតុជីវៈបសុព្យាបាល និងចំណីសត្វ<br>– អនុញ្ញាតលើការបង្កើតទីកន្លែងផលិត និងសន្និធិផលិតផលសត្វជាលក្ខណៈពាណិជ្ជកម្មខ្នាតធំ<br>– កំណត់បញ្ជីបសុឱសថ និងវត្ថុធាតុជីវៈបសុព្យាបាលដែលអនុញ្ញាតឱ្យប្រើប្រាស់ និងមិនអនុញ្ញាតឱ្យប្រើប្រាស់<br>– អនុញ្ញាតលើការនាំចេញ នាំចូលបសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល និងចំណី | លិត និងសន្និធិផលិតផលសត្វ ទីកន្លែងផលិតបសុឱសថ ចែកចាយ និងលក់បសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល និងចំណីសត្វលក្ខណៈពាណិជ្ជកម្មខ្នាតមធ្យម<br>– អនុញ្ញាតលើការបង្កើតសត្តឃាតដ្ឋានខ្នាតធំ (ក)<br>– ត្រួតពិនិត្យអនាម័យសាច់ និងផលិតផលសត្វក្នុងដែនសមត្ថកិច្ចរបស់ខ្លួន<br>– គ្រប់គ្រងមន្ទីរពិសោធន៍សម្រាប់សុខភាព និងផលិតផលសត្វនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន<br>– កំណត់ទីតាំង និងត្រួតពិនិត្យលើការបង្កើតស្ថានីយចត្តាឡីស័កសត្វនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន<br>– ត្រួតពិនិត្យសុខមាលភាពសត្វនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន<br>– ផ្សព្វផ្សាយ និងបណ្តុះបណ្តាលស្តីពីការការអភិវឌ្ឍវិស័យសុខភាពសត្វ និងផលិតកម្មសត្វនៅក្នុង | ត និងសន្និធិផលិតផលសត្វ ទីកន្លែងផលិតបសុឱសថ ចែកចាយ និងលក់បសុឱសថ វត្ថុធាតុជីវៈបសុព្យាបាល និងចំណីសត្វលក្ខណៈពាណិជ្ជកម្មខ្នាតតូច<br>– អនុញ្ញាតលើការបង្កើតសត្តឃាតដ្ឋានខ្នាតតូច (ខ)<br>– ត្រួតពិនិត្យអនាម័យសាច់ និងផលិតផលសត្វក្នុងដែនសមត្ថកិច្ចរបស់ខ្លួន<br>– កំណត់ទីតាំង និងត្រួតពិនិត្យលើការបង្កើតស្ថានីយចត្តាឡីស័កសត្វនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន<br>– អនុញ្ញាតលើការបង្កើតទីកន្លែងព្យាបាលសត្វ កន្លែងប្រមូលផ្តុំសត្វ និងអាជីវកម្មសត្វនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន<br>– ផ្សព្វផ្សាយ និងបណ្តុះបណ្តាលស្តីពីការការអភិវឌ្ឍវិស័យសុខភាពសត្វ និងផលិតកម្មសត្វនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន<br>– ចូលរួម ចាត់វិធានការពារ និងទប់ | |

| ល.រ | មុខងារ/កិច្ចការ | រដ្ឋបាលថ្នាក់ជាតិ | រដ្ឋបាលថ្នាក់ខេត្ត | រដ្ឋបាលថ្នាក់ក្រុងស្រុក | ដំណាក់កាលផ្ទេរ |
|---|---|---|---|---|---|
| | | សត្វ<br>– កំណត់បទដ្ឋានបច្ចេកទេសសម្រាប់ការបង្កើតសត្តឃាតដ្ឋាន និងសម្រាប់ការត្រួតពិនិត្យសាច់ និងផលិតផលសត្វ<br>– កំណត់បទដ្ឋានបច្ចេកទេសសម្រាប់ការបង្កើតមន្ទីរពិសោធន៍សម្រាប់សុខភាព និងផលិតផលសត្វ<br>– គ្រប់គ្រងមន្ទីរពិសោធន៍សម្រាប់សុខភាព និងផលិតផលសត្វកម្រិតថ្នាក់ជាតិ<br>– ពិនិត្យអនាម័យសាច់ និងផលិតផលសត្វសម្រាប់ការនាំចេញ និងនាំចូល<br>– កំណត់បទដ្ឋានបច្ចេកទេស និងទីតាំងបង្កើតស្ថានីយចត្តាឡីស័កសត្វសម្រាប់ការនាំចេញ និងនាំចូលសត្វ<br>– កំណត់បទដ្ឋានបច្ចេកទេសសម្រាប់ការបង្កើតទីកន្លែងព្យាបាលសត្វ កន្លែងប្រមូលផ្តុំសត្វ និងអាជីវកម្មសត្វ<br>– កំណត់បទដ្ឋានបច្ចេកទេសសម្រាប់ការត្រួតពិនិត្យសុខុមាលភាពសត្វ<br>– សិក្សា ស្រាវជ្រាវ និងផ្សព្វផ្សាយការអភិវឌ្ឍវិស័យសុខភាពសត្វ និងផលិតកម្មសត្វកម្រិតថ្នាក់ជាតិ | ដែនសមត្ថកិច្ចរបស់ខ្លួន<br>– ចាត់វិធានការពារ និងទប់ស្កាត់បទល្មើសនានាពាក់ព័ន្ធនឹងវិស័យសុខភាពសត្វ និងផលិតកម្មសត្វនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ | ស្កាត់បទល្មើសនានាពាក់ព័ន្ធនឹងវិស័យសុខភាពសត្វ និងផលិតកម្មសត្វនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន | |

## V. បញ្ជីមុខងារក្នុងវិស័យសង្គមកិច្ចដែលត្រូវផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ

| ល.រ | មុខងារ/កិច្ចការ | រដ្ឋបាលថ្នាក់ជាតិ | រដ្ឋបាលថ្នាក់រាជធានី ខេត្ត | រដ្ឋបាលថ្នាក់ក្រុង ស្រុក ឃុំ | ដំណាក់កាលផ្ទេរ |
|---|---|---|---|---|---|
| ១ | ការគ្រប់គ្រងមណ្ឌលថែទាំកុមាររបស់រដ្ឋ | – រៀបចំគោលនយោបាយ ស្តង់ដារសេវា លិខិតបទដ្ឋាន<br>– ផ្តល់ការបណ្តុះបណ្តាល និងគាំទ្របច្ចេកទេស<br>– កៀរគរធនធានគាំទ្រពីប្រភពនានា<br>– ត្រួតពិនិត្យ និងវាយតម្លៃគុណភាពសេវា<br>– តាមដាន ត្រួតពិនិត្យ វាយតម្លៃលើការអនុវត្ត | – គ្រប់គ្រងមណ្ឌលថែទាំកុមារកំព្រារបស់រដ្ឋស្របតាមគោលនយោបាយ ស្តង់ដារ និងលិខិតបទដ្ឋានគតិយុត្តនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន | | ឆ្នាំ២០១៧ ប្រគល់ទៅឱ្យរដ្ឋបាលរាជធានី ខេត្តទូទាំងប្រទេស |
| ២ | ការត្រួតពិនិត្យមណ្ឌលថែទាំកុមាររបស់អង្គការមិនមែន រដ្ឋាភិបាល | – រៀបចំគោលនយោបាយ ស្តង់ដារសេវា លិខិតបទដ្ឋាន<br>– ផ្តល់ការបណ្តុះបណ្តាល និងគាំទ្របច្ចេកទេស<br>– កៀរគរធនធានគាំទ្រពីប្រភពនានា<br>– ត្រួតពិនិត្យ និងវាយតម្លៃគុណភាពសេវា<br>– តាមដាន ត្រួតពិនិត្យ វាយតម្លៃលើការអនុវត្ត | – ត្រួតពិនិត្យមណ្ឌលថែទាំកុមារកំព្រាដែលគ្រប់គ្រងដោយអង្គការមិនមែន រដ្ឋាភិបាលក្នុងដែនសមត្ថកិច្ចរបស់ខ្លួន (សម្រាប់រដ្ឋបាលរាជធានី) | – ត្រួតពិនិត្យមណ្ឌលថែទាំកុមារកំព្រា ដែលគ្រប់គ្រងដោយអង្គការមិនមែន រដ្ឋាភិបាលក្នុងដែនសមត្ថកិច្ចរបស់ខ្លួន (សម្រាប់រដ្ឋបាលក្រុង ស្រុក) | ឆ្នាំ២០១៧ ប្រគល់ទៅឱ្យរដ្ឋបាលរាជធានី ក្រុង ស្រុកទូទាំងប្រទេស |
| ៣ | ការគ្រប់គ្រងសេវាថែទាំកុមាររងគ្រោះ និងងាយរងគ្រោះនៅក្នុងសហគមន៍ | – រៀបចំស្តង់ដារសេវា លិខិតបទដ្ឋាន<br>– ផ្តល់ការបណ្តុះបណ្តាល និងគាំទ្របច្ចេកទេស<br>– កៀរគរធនធានគាំទ្រពីប្រភពនានា<br>– ត្រួតពិនិត្យនិងវាយតម្លៃគុណភាពសេវា<br>– តាមដាន ត្រួតពិនិត្យ វាយតម្លៃលើការអនុវត្ត | – គ្រប់គ្រងសេវាថែទាំកុមាររងគ្រោះ និងងាយរងគ្រោះនៅក្នុងសហគមន៍ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន (សម្រាប់រដ្ឋ បាលរាជធានី) | – គ្រប់គ្រងសេវាថែទាំកុមាររងគ្រោះ និងងាយរងគ្រោះនៅក្នុងសហគមន៍ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន (សម្រាប់រដ្ឋបាលក្រុង និងឃុំ) | ឆ្នាំ២០១៧ ប្រគល់ទៅឱ្យរដ្ឋបាលរាជធានី ក្រុង និងឃុំទូទាំងប្រទេស |

## VI. បញ្ជីមុខងារក្នុងវិស័យទេសចរណ៍ដែលត្រូវផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ

| ល.រ | មុខងារ/កិច្ចការ | រដ្ឋបាលថ្នាក់ជាតិ | រដ្ឋបាលថ្នាក់រាជធានី ខេត្ត | រដ្ឋបាលថ្នាក់ក្រុងស្រុក | ដំណាក់កាលផ្ទេរ |
|---|---|---|---|---|---|
| ១ | **ការងារឧស្សាហកម្មទេសចរណ៍** | - កំណត់ចំណាត់ថ្នាក់សណ្ឋាគារ និងសេវាស្នាក់នៅ<br>- កំណត់ស្តង់ដារសម្រាប់ការគ្រប់គ្រងការងារឧស្សាហកម្មទេសចរណ៍ (សណ្ឋាគារ ផ្ទះសំណាក់ សេវាស្នាក់នៅ និងសេវាទេសចរណ៍ផ្សេងទៀត)<br>- សិក្សាស្រាវជ្រាវសម្រាប់ការពង្រឹងសេវាកម្មទេសចរណ៍។ | - គ្រប់គ្រងមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ (សម្រាប់រាជធានី) លើកលែងមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យដែលមានលក្ខណៈស្តង់ដា ឬស្ថិតនៅក្នុងសណ្ឋាគារមាន ចំណាត់ថ្នាក់ចាប់ពីផ្កាយ៤ឡើង និងមុខងារដែលបានធ្វើប្រតិភូកម្មទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ<br>- ម៉ាស្សា (លើកលែងតែមានលក្ខណៈស្តង់ដា ឬស្ថិតនៅក្នុងសណ្ឋាគារមានចំណាត់ថ្នាក់ចាប់ពីផ្កាយ៤ឡើង និងមុខងារដែលបានធ្វើប្រតិភូកម្មទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ)<br>- សណ្ឋាគារ ម៉ូតែល បឹងហ្គាឡូ ឡូត៏ អឺជាតមិនត្រឹម២០បន្ទប់ចុះក្រោម<br>- ផ្ទះសំណាក់ត្រឹម២០បន្ទប់ចុះ លើកលែងមុខងារដែលបានធ្វើប្រតិភូកម្មទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ<br>- ភោជនីយដ្ឋាន អាហារដ្ឋានទេសចរណ៍ក្រោម១០០កៅអីចុះមិនស្ថិតនៅក្នុងសណ្ឋាគារ និងមុខងារដែលបានធ្វើប្រតិភូកម្មទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ | | ឆ្នាំ២០១៦បានធ្វើប្រតិភូកម្ម ទៅឱ្យរដ្ឋបាលធានីខេត្តទូទាំងប្រទេស |

| ល.រ | មុខងារ/កិច្ចការ | រដ្ឋបាលថ្នាក់ជាតិ | រដ្ឋបាលថ្នាក់រាជធានី ខេត្ត | រដ្ឋបាលថ្នាក់ក្រុងស្រុក | ដំណាក់កាលផ្ទេរ |
|---|---|---|---|---|---|
| | | | - កាណូតទេសចរណ៍(លើកលែងតែកាណូតដឹកជញ្ជូនលក្ខណៈអន្តរជាតិ)<br>- មគ្គុទ្ទេសក៍ទេសចរណ៍(មគ្គុទេសក៍ទេសចរណ៍ថ្នាក់ក្រោមជាតិ និងមគ្គុទេសក៍ទេសចរណ៍សហគមន៍) | | |
| ២ | **ការងារអភិវឌ្ឍទេសចរណ៍** | - រៀបចំគោលនយោបាយ គោលការណ៍ និងបទដ្ឋានសម្រាប់ការវិនិយោគ និងការអភិវឌ្ឍទេសចរណ៍ក្នុងប្រទេស<br>- សិក្សា ស្រាវជ្រាវដើម្បីពង្រីកគោលដៅទេសចរណ៍ និងផលិតផលទេសចរណ៍នៅក្នុងប្រទេស<br>- កៀរគរការវិនិយោគ និងការអភិវឌ្ឍតំបន់ទេសចរណ៍<br>- សិក្សាទីផ្សារ និងផ្សព្វផ្សាយអំពីវិស័យទេសចរណ៍<br>- ត្រួតពិនិត្យព័ត៌មានទេសចរណ៍<br>- កំណត់ស្តង់ដាចំណាត់ថ្នាក់រមណីយដ្ឋានទេសចរណ៍ និងសហគមន៍ទេសចរណ៍។ | - គ្រប់គ្រងរមណីយដ្ឋានទេសចរណ៍ លើកលែងតែរមណីយដ្ឋានទេសចរណ៍ដែលមានលក្ខណៈស្តង់ដារ និងចំណាត់ថ្នាក់<br>- គ្រប់គ្រងសហគមន៍ទេសចរណ៍ | | ឆ្នាំ២០១៧ ធ្វើប្រតិភូកម្មទៅឱ្យរដ្ឋបាលធានី ខេត្តទូទាំងប្រទេស |

## VII. បញ្ជីមុខងារក្នុងវិស័យធនធានទឹកដែលត្រូវផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ

| ល.រ | មុខងារ/កិច្ចការ | រដ្ឋបាលថ្នាក់ជាតិ | រដ្ឋបាលថ្នាក់ខេត្ត | រដ្ឋបាលថ្នាក់ក្រុងស្រុក | ដំណាក់កាលផ្ទេរ |
|---|---|---|---|---|---|
| ១ | ការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ | – រៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រជាតិ និងលិខិតបទដ្ឋានគតិយុត្ត<br>– កំណត់បទដ្ឋានបច្ចេកទេសសម្រាប់ការសាងសង់ ការជួសជុល ការថែទាំ និងការប្រើប្រាស់ធារាសាស្ត្រ<br>– ផ្សព្វផ្សាយ និងបណ្តុះបណ្តាល<br>– ការគ្រប់គ្រងការសាងសង់ ជួសជុល ថែទាំ និងប្រើប្រាស់ប្រព័ន្ធធារាសាស្ត្រដែលមានសមត្ថភាពស្រោចស្រពចាប់ពី៣.០០០ ហិចតាឡើង<br>– តាមដាន ត្រួតពិនិត្យ និងអធិការកិច្ចលើការសាងសង់ ការជួសជុល ការថែទាំ និងការប្រើប្រាស់ប្រព័ន្ធធារាសាស្ត្រ។ | – ការគ្រប់គ្រងការសាងសង់ ជួសជុល ថែទាំ និងប្រើប្រាស់ប្រព័ន្ធធារាសាស្ត្រដែលមានសមត្ថភាពស្រោចស្រពចាប់ពី៥០០ហិចតាដល់៣.០០០ហិចតា | – ការគ្រប់គ្រងការសាងសង់ ជួសជុល ថែទាំ និងប្រើប្រាស់ប្រព័ន្ធធារាសាស្ត្រដែលមានសមត្ថភាពតំបន់ស្រោចស្រពតិចជាង ៥០០ហិចតា។ | |